# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jun-2012, 15:30
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ សាធារណៈ:

ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ/Public**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ

អង្គជំនុំជម្រះ

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើសុំឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ទាក់ទិននឹងការកោះហៅសាក្សី ដែលបានស្នើឡើងដោយមេធាវីការពារក្តី

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

**ចម្លងជូន:**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

ព្រុំ ផល្លា
Jacqueline GREENE
Scarlet WAGNER
Devika KAMP

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
**ពេជ អង្គ**
Elisabeth SIMONNEAU FORT

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៩២ មេធាវីការពារក្តី នួន ជា (“មេធាវីការពារក្តី”) សូមដាក់សំណើនេះ (“សំណើ”) សុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយលើបញ្ហាថាតើ សាក្សីដែលស្នើឡើងដោយមេធាវីការពារក្តីដែលនៅសេសសល់នឹងត្រូវកោះហៅមកធ្វើសាក្សីកម្ម ដែរ ឬយ៉ាងណា។ សវនាការនេះត្រូវរៀបចំឱ្យបានកាន់តែឆាប់រហ័សតាមតែអាចធ្វើទៅបាន ដើម្បីសម្រាលផលប៉ះពាល់ជាអវិជ្ជមានទានាបន្ថែមទៀតទៅលើភាគីខាងមេធាវីការពារក្តី ដែលបណ្តាលមកពីការពន្យារពេលក្នុងការសម្រេចលើបញ្ជីឈ្មោះសាក្សីស្តាពរ។ សំណើនេះត្រូវបានគាំទ្រដោយវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) សិទ្ធិទទួលបានសវនាការសាធារណៈ សិទ្ធិទទួលការការពារខ្លួន និងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី។

## II. ប្រវត្តិនីតិវិធី

២. មេធាវីការពារក្តីធ្លាប់បានស្នើទៅអង្គជំនុំជម្រះសាលាដំបូង រួចមកហើយសុំឱ្យមានសវនាការផ្ទាល់មាត់ ដែលត្រូវរៀបចំជាសាធារណៈ ដើម្បីអនុញ្ញាតឱ្យភាគីបង្ហាញទឡ្ហីករណ៍របស់ខ្លួនគាំទ្រ និងប្រឆាំងនឹងការស្តាប់សក្ខីកម្មសាក្សីមួយចំនួន ដែលបានស្នើឡើងដោយមេធាវីការពារក្តី[១]។ មកទល់

[១] *សូមមើល* ឯកសារលេខ **E1/4.1**, “ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ”, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១, លេខ ERN 00712135–0071252, pp 12:13–17:7 ៖ “**លោក Michiel PESTMAN៖** សូមអរគុណលោកប្រធាន។ ដូចដែលកូនក្តីរបស់ខ្ញុំបានពន្យល់ហើយ ថាគាត់មិនសប្បាយចិត្តទេ ខ្ញុំសូមពន្យល់ថា ហេតុអ្វីបានជាគាត់មិនសប្បាយចិត្ត។ [...] យើងខ្ញុំក៏បានសុំឱ្យកោះហៅសាក្សីជាង៣០០នាក់ដែលយើងគិតថា ជាសាក្សីដែលគួរតែត្រូវបានគេស្តាប់ចម្លើយជាសាធារណៈ។ ពោលគឺជាសាក្សីដែលបានដឹងពីបរិបទប្រវត្តិសាស្ត្រសម្រាប់តុលាការនេះ ក៏ដូចជាបរិបទជម្លោះសម្រាប់សាក្សីធ្វើសក្ខីកម្មទៅលើបញ្ហាស៊ើបអង្កេត។ យើងមិនដឹងថា តើហេតុអ្វីបានជាយើងត្រូវចូលរួមនៅក្នុងសវនាការនៅពេលនេះទេ?” អង្គជំនុំជម្រះសាលាដំបូងបានកំណត់នូវរបៀបវារៈសម្រាប់រយៈពេលសវនាការចំនួនបួនថ្ងៃ ដែលមិនបានអញ្ជើញត្រកម្មណាមួយ ឬក៏សាក្សីណាមួយដែលលោក នួន ជា បានស្នើឡើងត្រូវបានលើកមកពិភាក្សានោះទេ។ ទោះបីជាវិធានតុលាការនេះបានចែងថា បញ្ហាទាំងអស់នេះនឹងត្រូវយកមកពិភាក្សានៅសវនាការបែបនេះក៏ដោយ [...] ហើយ[នួន ជា] ជឿជាក់ថា ពួកគាត់គួរតែត្រូវបានអនុញ្ញាតឱ្យតាមរយៈសាក្សីទាំងអស់ គាត់គួរតែត្រូវបានអនុញ្ញាតឱ្យពន្យល់ពីមូលហេតុ ដែលសាក្សីទាំងអស់របស់គាត់គួរតែត្រូវមកផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះក្តីនេះ។ ហើយសំខាន់ជាងនេះទៅទៀត គឺលោក នួន ជា ជឿជាក់ថា ការពិភាក្សាទាំងអស់នេះត្រូវតែធ្វើឡើងជាសាធារណៈ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា។ [...] យើងចង់ឱ្យមានការពិភាក្សាជាមូលដ្ឋានអំពីការស៊ើបអង្កេតដែលមានមូលដ្ឋានគ្រឹះសម្រាប់តុលាការនៅពេលអនាគត និងពិភាក្សាអំពីសាក្សីដែលត្រូវស្តាប់ចម្លើយនៅក្នុងពេលសវនាការ។ [...] គាត់នឹងចាកចេញពីបន្ទប់នេះ ហើយគាត់នឹងត្រឡប់មកវិញចូលរួមទៅក្នុងសវនាការជាមួយអង្គជំនុំជម្រះសាលាដំបូងនេះ

នឹងពេលនេះ អង្គជំនុំជម្រះសាលាដំបូងពុំទាន់អនុញ្ញាតឱ្យមានទង្គីករណ៍បែបនេះនៅឡើយទេ។

## III. ច្បាប់ពាក់ព័ន្ធ

### ក. តម្រូវការឱ្យមានសវនាការស្តីពីការកោះហៅសាក្សី

៣. តាមវិធាន ៨០*ស្ទួន* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះត្រូវពិភាក្សាសម្រេចទៅលើបញ្ជីឈ្មោះសាក្សី ក្នុងចំណោមបញ្ហាដទៃទៀត នៅឯសវនាការបឋម។ វិធាននោះចែងថា៖ "សវនាការបឋម ... [...] *នៅក្នុងពេលសវនាការបឋមនេះ* អង្គជំនុំជម្រះសាលាដំបូងត្រូវ*ពិចារណា*អំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលដាក់ជូនដោយភាគី ស្របតាមវិធានផ្ទៃក្នុងនេះ។ នៅពេលអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ការស្តាប់សាក្សី ឬ អ្នកជំនាញដែលត្រូវបានស្នើសុំនឹងមិននាំមកនូវដំណើរការល្អនៃការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធសំណើសុំឱ្យកោះហៅបុគ្គល

---

នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងពិភាក្សាអំពីអញ្ញត្រកម្ម និងសាក្សីដែលគាត់បានលើកឡើង។ ហើយប្រសិនបើមិនមានសវនាការបែបនោះមែននៅសប្តាហ៍នេះ សវនាការបឋមគួរប្រព្រឹត្តទៅនៅសប្តាហ៍បន្ទាប់។ កូនក្តីយើងខ្ញុំមិនចង់ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនេះទេ គាត់នឹងចូលរួមនៅក្នុងសវនាការនេះ លុះត្រាតែអញ្ញត្រកម្មរបស់គាត់ និងសាក្សីទាំងអស់របស់គាត់ មិនត្រឹមតែសាក្សីដែលមានឈ្មោះក្នុងស្រោមសំបុត្រនេះទេ តែគឺសាក្សីទាំងអស់ត្រូវបានបញ្ចូលទៅក្នុងរបៀបវារៈ ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងនៃតុលាការនេះ"។ *សូមមើលផងដែរ* ឯកសារលេខ **E1/7.1**, "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ", ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១, លេខ ERN 00713767–00713819, pp 17:24–18:13 ៖ "**លោក Victor KOPPE៖** លោកប្រធាន ខ្ញុំយល់លោកប្រធានបានច្បាស់ គឺថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា យើងមិនត្រូវបានអនុញ្ញាតឱ្យនិយាយអំពីការជ្រើសរើសបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ននោះទេ។ ដូចដែលខ្ញុំបានបញ្ជាក់ជូនអង្គជំនុំជម្រះអ៊ីចឹងថា ប្រហែលជាខ្ញុំត្រូវការពេលវេលា ៣០ នាទីតែប៉ុណ្ណោះ ដើម្បីលើកឡើងអំពីបញ្ហាសំខាន់ៗដែលពាក់ព័ន្ធទាំងឡាយទាក់ទិននឹងសាក្សីនេះ។ កូនក្តីរបស់ខ្ញុំបានរង់ចាំបួនថ្ងៃហើយសម្រាប់ឱ្យយើងមានឱកាស ៣០នាទីនេះដើម្បីលើកឡើង ...។ **ប្រធានអង្គជំនុំជម្រះ៖** ពេលនេះ ពីព្រោះយើងបានជម្រាបជូនលោករួចមកហើយថា មិនឱ្យលោកនិយាយប្រាសចាកនូវរបៀបវារៈដែលបានកំណត់ទេ ហើយអង្គជំនុំជម្រះនឹងមិនអនុញ្ញាតឱ្យលោកនិយាយ ឬឆ្លៀតឱកាសនេះដើម្បីលើកយកបញ្ហាដទៃទៀតដែលមិនពាក់ព័ន្ធនឹងបញ្ជីឈ្មោះសាក្សី [បណ្តោះអាសន្ន] យកមកពិភាក្សាទេ [...]"។ *សូមមើលផងដែរ ដូចយោងខាងលើ* p 37:2–14៖ "**លោក Victor KOPPE៖** សូមអរគុណលោកប្រធាន។ យើងខ្ញុំមានសំណើតែមួយទេ ដើម្បីសូមឱ្យមានការបញ្ជាក់ ដែលតាមការពិតដែលត្រូវពិភាក្សានៅមុខសាធារណជន ដែលសំណើសុំឱ្យមានការបញ្ជាក់នេះ គឺអំពីវិធាន ៨០(ខ) ស្តីអំពីសវនាការបឋម។ យើងខ្ញុំយល់ថា បទប្បញ្ញត្តិចែងថា៖ "អង្គជំនុំជម្រះនៅក្នុងសវនាការបឋមត្រូវពិចារណាអំពីបញ្ជីឈ្មោះសាក្សីសំខាន់ៗមួយចំនួន"។ យើងខ្ញុំយល់អំពីបទប្បញ្ញត្តិនៅក្នុងវិធាននេះ ដែលថាក្នុងសវនាការបឋម ជាពេលដែលត្រូវពិចារណាជាសាធារណៈទៅលើសំណើសុំកោះហៅសាក្សីពីភាគីនានា ហើយថា សហព្រះរាជអាជ្ញាអាចជំទាស់ទៅនឹងសាក្សីដែលស្នើដោយជនជាប់ចោទបាន ហើយថា យើងខ្ញុំក៏អាចជំទាស់ទៅនឹងសាក្សីដែលស្នើឡើងដោយសហព្រះរាជអាជ្ញាដែរ"។

នោះ”។ វិធានផ្ទៃក្នុងពុំអនុញ្ញាតឲ្យ*ពិចារណា*ទៅលើបញ្ជីឈ្មោះសាក្សី នៅដំណាក់កាលណាផ្សេង ក្រៅពីនៅដំណាក់កាលសវនាការបឋមទេ។

## ខ. សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទក្នុងការទទួលបានសវនាការជាសាធារណៈ

៤. សិទ្ធិទទួលបានសវនាការជាសាធារណៈ ត្រូវបានធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[២] អនុសញ្ញាសិទ្ធិមនុស្សប្រចាំទ្វីបអឺរ៉ុប (ECHR)[៣] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)[៤] និងពីតុលាការ និងសាលាជម្រះក្តីអន្តរជាតិ និងមានលក្ខណៈអន្តរជាតិទាំងអស់[៥]។ មាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏តម្រូវស្រដៀងគ្នាដែរថា៖ “សវនាការត្រូវធ្វើជាសាធារណៈ និងបើកចំហសម្រាប់តំណាង” សហគមន៍ជាតិ និងអន្តរជាតិ។ វិធាន ៧៩(៦) កំណត់ឲ្យមាន*ការផ្សព្វផ្សាយជាសាធារណៈ* នូវសវនាការជាសាធារណៈទាំងអស់នៅ អ.វ.ត.ក[៦]។ អង្គជំនុំជម្រះអាចសម្រេចរៀបចំសវនាការ*សម្ងាត់*បាន តែក្នុងករណីដែលអង្គជំនុំជម្រះសម្រេចដោយចេញសេចក្តីសម្រេច ដែលមានសំអាងហេតុច្បាស់លាស់ដែលថា សវនាការបែបនេះជាការចាំបាច់សម្រាប់រក្សាសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីឲ្យវិធានការការពារមានប្រសិទ្ធភាពតែប៉ុណ្ណោះ[៧]។

៥. សិទ្ធិទទួលបានសវនាការជាសាធារណៈអនុវត្តចំពោះសវនាការ លើការកោះហៅសាក្សីតាមវិធាន

---

[២] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(១)៖ “ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ...”។

[៣] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, មាត្រា ៦(១)៖ “ក្នុងការសម្រេចពីសិទ្ធិ និងកាតព្វកិច្ចក្នុងវិស័យរដ្ឋប្បវេណី ឬ ក្នុងវិស័យព្រហ្មទណ្ឌប្រឆាំងនឹងខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានសវនាការប្រកបដោយយុត្តិធម៌ និងជាសាធារណៈ ក្នុងពេលវេលាមួយដែលសមរម្យ ដោយតុលាការឯករាជ្យ និងមិនលម្អៀងដែលបង្កើតដោយច្បាប់ ...”។

[៤] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស, មាត្រា ១១(១)។

[៥] *សូមមើល* លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា ៦៧(១); លក្ខន្តិកៈតុលាការ ICTY, មាត្រា ២០(៤); លក្ខន្តិកៈតុលាការ ICTR, មាត្រា ២០(២); លក្ខន្តិកៈតុលាការ SCSL, មាត្រា ១៧(២); បញ្ញត្តិ UNTAET លេខ 2000/30 ស្តីពីវិធានបណ្តោះអាសន្ននៃនីតិវិធីព្រហ្មទណ្ឌ; ឯកសារលេខ UNTAET/REG/2000/30 (ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០០), § 2.1។

[៦] វិធាន ៧៩(៦)៖ (“ការពិភាក្សាដេញដោលរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវប្រព្រឹត្តទៅជាសាធារណៈ។ (ក) ការិយាល័យរដ្ឋបាលត្រូវធានានការផ្សព្វផ្សាយជាសាធារណៈនៃសវនាការ តែត្រូវគោរពដល់វិធានការការពារនានា ដែលមានចែងនៅក្នុងវិធាននេះ”)។

[៧] វិធាន ៧៩(៦)(ខ)។

៨០*ស្ទួន*។ សវនាការ (បឋម) លើបញ្ជីឈ្មោះសាក្សីគឺជាសវនាការមួយដូចសនាការដទៃទៀតដែលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ អនុលោមតាមមាត្រា ៣៤ថ្មី និងវិធាន ៧៩(៦) សវនាការ (បឋម) ចាំបាច់ត្រូវក្លាយជាផ្នែកមួយនៃការជំនុំជម្រះជាសាធារណៈមួយ ដែលពេញលេញ ហើយត្រូវតែផ្សព្វផ្សាយដល់សាធារណជន។

៦. នៅក្នុង*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Delalić តុលាការ ICTY បានពិភាក្សាពីសទិទានភាពនៅពីក្រោយការតម្រូវឱ្យមានសវនាការជាសាធារណៈ និងពីលក្ខណៈជាមូលដ្ឋាននៃសិទ្ធិនោះ ដោយកត់សម្គាល់ថា៖

> គុណប្រយោជន៍សំខាន់នៃការអនុញ្ញាតឱ្យសាធារណជន និងសារព័ត៌មានចូលរួមក្នុងសវនាការមួយគឺថា វត្តមានរបស់អ្នកទាំងនោះជួយផ្តល់នូវការធានាឱ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ នៅក្នុង*រឿងក្តី Pretto & Ors តទល់នឹង ប្រទេសអ៊ីតាលី* (Series A, No. 71 (1984) 6 EHRR 182) តុលាការ ECHR បានលើកឡើងថា "មតិសាធារណៈត្រូវបានគេចាត់ទុកថា ជាការធានានូវភាពត្រឹមត្រូវនៃការជំនុំជម្រះក្តី វាផ្តល់នូវការការពារប្រឆាំងនឹងការសម្រេចសេចក្តីមិនត្រឹមត្រូវ និងស្ថាបនាជំនឿជាក់ ដោយអនុញ្ញាតឱ្យសាធារណជនបាននូវយុត្តិធម៌ ដែលមានដំណើរការត្រឹមត្រូវ"។ ហេតុនេះ សវនាការជាសាធារណៈ ជាសំខាន់គឺសម្រាប់ជាផលប្រយោជន៍ដល់ជនជាប់ចោទ និងមិនចាំបាច់សម្រាប់សាធារណជននោះទេ[៨]។

សេចក្តីសម្រេចក្នុងរឿងក្តី *Delalić* បានសង្កត់ធ្ងន់នូវសារៈសំខាន់នៃការធានាប្រឆាំងនឹងការសម្រេចចិត្តមិនត្រឹមត្រូវ និងលើកស្ទួយតម្លៃនៃការពិនិត្យពិច័យរបស់សាធារណជនចំពោះកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះក្តី។ សិទ្ធិទទួលបានសវនាការជាសាធារណៈតម្រូវឱ្យតុលាការធ្វើឱ្យមានការចូលរួមការពិភាក្សា ការលើកឡើងទឡ្ហីករណ៍ និងការសម្រេចសេចក្តីជាសាធារណៈឱ្យបានក្នុងកម្រិតជាអតិបរមា ដើម្បីធ្វើឱ្យមានការសម្រេចសេចក្តីប្រកបដោយមនសិការ មានតម្លាភាព និងសមហេតុសមផល ចំពោះបញ្ហានានាដែលមាននៅចំពោះមុខតុលាការ។

---

[៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Delalić, សំណុំរឿងលេខ IT-96-21 "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាដែលស្នើសុំឱ្យមានវិធានការការពារសម្រាប់សាក្សីដែលស្នើឡើងដោយរដ្ឋអាជ្ញាមានរហស្សនាមពី "B" ដល់ "M", ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧, ត្រង់កថាខណ្ឌ ៣៤។

## គ. សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី

៧. គោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី ប្រគល់អាណត្តិឱ្យអង្គជំនុំជម្រះសាលាដំបូងក្នុងការធានាថា លោក នួន ជា ទទួលបាន "ឱកាសសមហេតុផលមួយដើម្បីការពារខ្លួន រួមទាំងភស្តុតាងរបស់ខ្លួនផង ក្រោមលក្ខខណ្ឌដែលមិនធ្វើឱ្យគាត់បាត់បង់អត្ថប្រយោជន៍ក្នុងការតទល់នឹងគូបដិបក្ខរបស់គាត់ទេ"[៩]។ សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី ដែលខុសពីសិទ្ធិការពារខ្លួន ត្រូវបានធានាដោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង និងកតិកាសញ្ញា ICCPR[១០]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសង្កេតពីមុនរួចមកហើយគឺថា "លក្ខណៈជាមូលដ្ឋាននៃគោលការណ៍នេះត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង"[១១]។ បើតាមតុលាការ ICTY "សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី ត្រូវតែផ្តល់នូវការបកស្រាយមួយដែលមានលក្ខណៈទូលំទូលាយជាងការបកស្រាយដែលត្រូវបានតម្កល់ជាធម្មតា ទាក់ទិននឹងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខតុលាការជាតិ"[១២]។

## ឃ. សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការការពារខ្លួន

---

[៩] សំណុំរឿងលេខ IT-94-1-A, *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić,* "សាលក្រម" ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៤៨, ដោយដកស្រង់ចេញពី *រឿងក្តី Dombo Beheer B.V. តទល់នឹង ប្រទេសហូឡង់,* ECtHR (14448/88), "សាលក្រម" ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៤០ (គូសបញ្ជាក់បន្ថែម)។

[១០] វិធាន ២១(១)(ក) ("ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ") *សូមមើលផងដែរ* ICCPR, មាត្រា ១៤(១)("(១)ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី...។ (៣)ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមាដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម៖ ... (ង)ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក ..."; ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ថ្មី។

[១១] សំណុំរឿងលេខ ០០១/០៨-០៧-២០០៧-អវតក/អជសដ, ឯកសារលេខ **E90** "សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់សារណាដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម", ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩, លេខ ERN 00345178-00345180, កថាខណ្ឌ ៤។

[១២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić,* សំណុំរឿងលេខ IT-94-1-A, "សាលក្រម", ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៥១-៥២។

៨. ដូចដែលមេធាវីការពារក្តីធ្លាប់បានលើកឡើងរួចមកហើយថា[១៣] សិទ្ធិក្នុងការការពារខ្លួនត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាសិទ្ធិមូលដ្ឋាន ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ទាំងនៅក្នុងយុត្តាធិការតុលាការជាតិ និងច្បាប់អន្តរជាតិ។ ក្នុងការអនុវត្តសិទ្ធិនេះ ជនជាប់ចោទមានសិទ្ធិបង្ហាញសាក្សី និងភស្តុតាងដទៃទៀត និងលើកឡើងនូវការការពារខ្លួនក្នុងអំឡុងពេលដំណើរការជំនុំជម្រះក្តី។ សិទ្ធិការពារខ្លួនធានាថាជន ជាប់ចោទទទួលបានការអនុញ្ញាតឲ្យបង្កើតទ្រឹស្តីរបស់ខ្លួននៃរឿងក្តី ដោយប្រើប្រាស់ភស្តុតាងរបស់ខ្លួន រួមទាំងសក្ខីកម្មពីសាក្សីដោះបន្ទុកនានាផងដែរ ក្នុងការតបតនឹងទ្រឹស្តីរបស់សហព្រះរាជអាជ្ញា។ តាមនិយមន័យ ទ្រឹស្តីនេះអាចចាំបាច់ពាក់ព័ន្ធនឹងទស្សនវិស័យ និងបញ្ហានានាដែលមិនត្រូវបានពិចារណានៅក្នុងទ្រឹស្តីនៃរឿងក្តីនេះរបស់សហព្រះរាជអាជ្ញា រួមទាំងព័ត៌មានបន្ថែម និងការពន្យល់ជាជម្រើសផ្សេងទៀតផង។

៩. សិទ្ធិការពារខ្លួនត្រូវបានការពារយ៉ាងច្បាស់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ក្រមនេះបានទទួលស្គាល់សិទ្ធិពេញលេញរបស់ជនជាប់ចោទក្នុងការកោះហៅសាក្សីដើម្បីផ្តល់ភស្តុតាងដោះបន្ទុក និងដើម្បីដាក់ជូនតុលាការនូវរាល់ភស្តុតាងទាំងអស់ដែលគាត់យល់ថាជួយស្វែងរកការពិត[១៤]។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទដើម្បី "ទទួលបានការបង្ហាញ និងពិនិត្យលើភស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងភស្តុតាងដាក់បន្ទុកដែរ" អនុលោមទៅតាមបទដ្ឋានអប្បបរមានៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលត្រូវបានធានាដោយកតិកាសញ្ញា ICCPR[១៥]។ ជាងនេះទៀត វិធានផ្ទៃក្នុងទទួលស្គាល់សិទ្ធិសម្រាប់ជនជាប់

---

[១៣] *សូមមើល* ឯកសារលេខ **E182** "សំណើសុំស្តាប់ចម្លើយសាក្សីដែលត្រូវបានស្នើដោយមេធាវីការពារក្តី និងចាត់ឲ្យមានវិធានការខាងនីតិវិធីដទៃទៀតដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្រ," ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១, លេខ ERN 00790415-00790430, កថាខណ្ឌ ១០-១៣។

[១៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៩៨៖ "ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយ ដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកសោហ៊ុយ")។ *សូមមើលផងដែរ ដូចយោងខាងលើ* មាត្រា ៣៣៤ ("រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ... អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ និងភស្តុតាងដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត")។

[១៥] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ថ្មី។

ចោទក្នុងការដាក់បញ្ជីឈ្មោះសាក្សីដែលពួកគេចង់កោះហៅ[១៦]។

១០. សិទ្ធិការពារខ្លួនត្រូវបានទទួលស្គាល់ជាយូរមកហើយនៅក្នុងច្បាប់អន្តរជាតិ ដោយចាប់តាំងពីតុលាការ Nuremberg មក[១៧]។ កតិកាសញ្ញា ICCPR[១៨] អនុសញ្ញា ECHR[១៩] និងលក្ខន្តិកៈទីក្រុងរ៉ូម ដែលបទប្បញ្ញត្តិទាំងអស់នេះចែងថា ជនជាប់ចោទមានសិទ្ធិការចូលរួមរបស់សាក្សីដោះបន្ទុក និងការសាកសួរសាក្សី។ លក្ខន្តិកៈទីក្រុងរ៉ូមបង្ហាញទៀតថា សិទ្ធិនេះរួមមានសិទ្ធិលើកឡើងនូវការការពារខ្លួន និងសិទ្ធិបង្ហាញភស្តុតាងដទៃទៀត[២០]។ ការលើកឡើងអំពីសិទ្ធិនៃការការពារខ្លួនមានចែងក្នុងយុត្តាធិការក្នុងស្រុកនៅទូទាំងពិភពលោក[២១]។

---

[១៦] វិធាន ៨០(២) ("នៅពេលដែលជនជាប់ចោទ និង/ឬ ក្រុមរួមគ្នានៃដើមបណ្តឹងរដ្ឋប្បវេណី មានបំណងកោះហៅសាក្សីណាម្នាក់ ដែលមិនមានឈ្មោះនៅក្នុងបញ្ជីដែលផ្តល់ឲ្យដោយសហព្រះរាជអាជ្ញា ជនជាប់ចោទ និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ជូនបញ្ជីឈ្មោះបន្ថែម")។

[១៧] ធម្មនុញ្ញទីក្រុងឡុងស្តីពីតុលាការយោធាអន្តរជាតិ, មាត្រា ១៦ ("ដើម្បីធានាការជំនុំជម្រះក្តីឲ្យបានត្រឹមត្រូវសម្រាប់ជនជាប់ចោទ គេត្រូវអនុវត្តតាមនីតិវិធីដូចតទៅ៖ [...] (ង) តាមរយៈខ្លួនផ្ទាល់ក្តី ឬតាមរយៈមេធាវីរបស់ខ្លួនក្តី ជនជាប់ចោទត្រូវមានសិទ្ធិបង្ហាញភស្តុតាងទៅតុលាការ ដើម្បីគាំទ្រការការពារខ្លួន ...")។

[១៨] កតិកាសញ្ញា ICCPR, មាត្រា ១៤(៣) ("ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមាដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម៖ ... (ង) [...] សុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក")។

[១៩] អនុសញ្ញា ECHR, មាត្រា ៦(៣) ("សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌៖ "៣.មនុស្សគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិអប្បបរមាដូចតទៅ៖ [...] (ឃ) [...]សុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក"។ សូមមើលផងដែរ *រឿងក្តី Vidal តទល់នឹង ប្រទេសបែលហ្ស៊ិក,* តុលាការ ECtHR (12351/86) ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩២ កថាខណ្ឌ ៣៤-៣៥ (ដោយបានសន្និដ្ឋានថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌តាមមាត្រា ៦ នៃអនុសញ្ញា ECHR ត្រូវបានរំលោភបំពាន នៅពេលដែលតុលាការខកខានមិនបានកោះហៅសាក្សីនានាដែលស្នើសុំដោយជនជាប់ចោទ)។

[២០] លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា ៦៧(១)(ង)។ សំណុំរឿងលេខ ICC-01/04-01/06, *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga Dyilo,* ប្រតិចារឹកស្តីពីការបង្ហាញខ្លួនលើកទីមួយ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦, ត្រង់ទំព័រ ៤, (ដោយតុលាការជូនដំណឹងទៅជនជាប់ចោទពីសិទ្ធិរៀបចំការការពារខ្លួន សំណើសុំនិងសាកសួរដេញដោលសាក្សី លើកឡើងនូវការការពារខ្លួន និងបង្ហាញភស្តុតាងផ្សេងទៀតក្នុងពេលសវនាការ) អាចរកបាននៅលើគេហទំព័រ៖ http://www.icc-cpi.int/iccdocs/doc/doc248955.pdf។

[២១] មាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មិនត្រឹមតែចែងពីសិទ្ធិរបស់ជនជាប់ចោទក្នុងការបង្ហាញបញ្ជីឈ្មោះសាក្សីដោះបន្ទុកប៉ុណ្ណោះទេ តែក៏មានចែងពីកាតព្វកិច្ចរបស់រដ្ឋអាជ្ញាក្នុងការកោះហៅសាក្សីដោះបន្ទុកទាំងនេះដែរ (ទោះបីកំហិតត្រឹម ៥ រូបក៏ដោយ) "Le ministère public et la partie civile signifient à l'accusé, l'accusé signifie au ministère public et, s'il y

១១. សន្និទានភាពនៅខាងក្រោយសិទ្ធិដំណើរការតាមផ្លូវច្បាប់ជាមូលដ្ឋាននេះ មានលក្ខណៈសាមញ្ញ។ ប្រសិនបើជនជាប់ចោទមិនអាចបង្ហាញសាក្សី និងភស្តុតាងរបស់ខ្លួន និងមិនអាចតទល់យ៉ាងមានប្រសិទ្ធភាពទៅនឹងទ្រឹស្តីរបស់សហព្រះរាជអាជ្ញា ចំពោះសំណុំរឿងដោយប្រើទ្រឹស្តីរបស់ខ្លួននេះទេ តុលាការនឹងទទួលបានការយល់ដឹងចំពោះអង្គហេតុតែមួយផ្នែក ឬបែបស្មានៗប៉ុណ្ណោះ។ លុះត្រាតែតុលាការបំពេញការងាររបស់ខ្លួនក្នុងការស្វែងរកការពិត បើមិនដូច្នោះទេ តុលាការនេះមិនអាចស្វែងរកយុត្តិធម៌បានទេ[២២]។

## ង. ប្រធានអង្គជំនុំជម្រះត្រូវធានាសិទ្ធិការពារខ្លួនដោយសេរីរបស់ជនជាប់ចោទ

១២. អនុលោមតាមវិធាន ៨៥៖ "ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវ [...] ធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនដោយសេរី"។ វិធាន ៨៥ ចែងពីកាតព្វកិច្ចរបស់ប្រធានអង្គជំនុំជម្រះក្នុងការធានាថា ជនជាប់ចោទបានប្រើប្រាស់សិទ្ធិ *ទាំងអស់*ដោយសេរី រួមទាំងសិទ្ធិនានាដែលបានពិភាក្សាខាងលើផងដែរ ដោយគ្មានការរាំងស្ទះ ឬការកំហិតជ្រុលហួសហេតុ។

## IV. <u>ឧទ្ទិករណ៍</u>

---

a lieu, à la partie civile, dès que possible et vingt-quatre heures au moins avant l'ouverture des débats, la liste des personnes qu'ils désirent faire entendre en qualité de témoins. […] [L]e ministère public est tenu de citer à sa requête les témoins, dont la liste lui a été communiquée par les parties […]; cette liste ne peut comporter plus de cinq noms"។ *សូមមើលផងដែរ*, រឿងក្តី Taylor តទល់នឹង, សំណុំរឿងលេខ 484 U.S. 400, 423-424 (ឆ្នាំ ១៩៨៨) (ដែលពិភាក្សាពីសារៈសំខាន់ចាំបាច់នៃសិទ្ធិការពារខ្លួននៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ស.រ.អា); ច្បាប់ស្តីពីកម្រងសិទ្ធិបុគ្គលនៃប្រទេសនូវែលហ្សេឡង់, មាត្រា ២៥(ច)25(f), សិទ្ធិ [...] ឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយដោះបន្ទុកក្នុងលក្ខខណ្ឌដូចគ្នានឹងការដាក់បន្ទុក")។ David S. Law & Mila Versteeg, ការវិវត្តន៍ និងមនោគមវិជ្ជានៃលទ្ធិរដ្ឋធម្មនុញ្ញនិយមជាសាកល (The Evolution and Ideology of Global Constitutionalism), 99 Cal. L. Rev. 1163, 1201, (ឆ្នាំ ២០១១) អាចរកបាននៅលើគេហទំព័រ៖ http://www.californialawreview.org/assets/pdfs/99-5/01-LawVersteeg.pdf, ដោយបានពិភាក្សាពីការស្ទាបស្ទង់មតិទៅលើរដ្ឋធម្មនុញ្ញចំនួន ១៨៨ ដែលក្នុងនោះ ៧២% មានចែងពីសិទ្ធិការពារខ្លួនតាមរដ្ឋធម្មនុញ្ញ)។

[២២] *រឿងក្តី Taylor តទល់នឹង Illinois*, សំណុំរឿងលេខ 484 U.S. 400, 423-424 (ឆ្នាំ ១៩៨៨) ("សិទ្ធិមួយចំនួនតូចមានលក្ខណៈជាមូលដ្ឋានគ្រឹះជាងសិទ្ធិរបស់ជនជាប់ចោទក្នុងការបង្ហាញសាក្សីដោះបន្ទុកទៅទៀត"។ ការដកចេញភស្តុតាងសម្រាប់ការពារក្តីក្នុងរឿងព្រហ្មទណ្ឌនាំឱ្យប៉ះពាល់ដល់ គោលបំណងចម្បងគឺការស្វែងរកការពិតនៅក្នុងប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌរបស់យើង ...។ ការពិត តម្លៃចម្បងនៃប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌរបស់យើងតម្រូវឱ្យដោះលែងជនគ្មានទោស ដោយតម្រូវឱ្យពិនិត្យពិច័យឱ្យបានហ្មត់ចត់ទៅលើច្បាប់នានាដែលរាំងគណៈវិនិច្ឆ័យមិនឱ្យស្តាប់សក្ខីកម្មនៃភស្តុតាងដោះបន្ទុក")។ (អត្ថបទដកស្រង់ខាងក្នុងបានត្រូវបានលុបចោល)

១៣. មេធាវីការពារក្ដីសូមលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើសវនាការមួយជាសាធារណៈ ដោយអនុលោមតាមវិធាន៨០ស្ទួន ដែលក្នុងនោះភាគីអាចលើកអំណះអំណាងគាំទ្រ និងជំទាស់ទៅនឹងសាក្សីដូចដែលមេធាវីការពារក្ដីបានស្នើសុំ[២៣]។ សវនាការនេះត្រូវបានតម្រូវដោយវិធានផ្ទៃក្នុង និងសិទ្ធិជាសារវន្តរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ មេធាវីការពារក្ដីសូមលើកឡើងថា សវនាការនេះគួរត្រូវបានធ្វើតាមរយៈការលើកទឡ្ហីករណ៍ផ្ទាល់មាត់នៅក្នុងសវនាការសាធារណៈជាចំហមួយ ហើយសវនាការនេះត្រូវធ្វើឆាប់ៗតាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានណាមួយ ទៅលើភាគីខាងមេធាវីការពារក្ដី ដែលបណ្ដាលមកពីការអូសបន្លាយពេលក្នុងការសម្រេចអំពីបញ្ជីឈ្មោះសាក្សីស្ដាពរ។

### ក. អង្គជំនុំជម្រះសាលាដំបូងត្រូវតែធ្វើសវនាការ ដោយអនុលោមតាមវិធាន ៨០ *ស្ទួន* និងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដើម្បីពិចារណាអំពីការកោះហៅសាក្សីនានាដែលមេធាវីការពារក្ដីបានស្នើសុំ

១៤. អង្គជំនុំជម្រះសាលាដំបូងត្រូវមានកាតព្វកិច្ចអនុលោមតាមវិធាន ៨០ *ស្ទួន* ក្នុងការរៀបចំសវនាការ ដើម្បីសម្រេចថាតើត្រូវកោះហៅសាក្សីដែលមានឈ្មោះក្នុងបញ្ជីឈ្មោះសាក្សីរបស់លោក នួន ជា ដែរ ឬយ៉ាងណា។ ទោះជាបែបនេះក្ដី នៅក្នុងសវនាការដំបូងរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបដិសេធពុំស្នើសុំឱ្យមានការលើកទឡ្ហីករណ៍ផ្ទាល់មាត់ស្ដីពីបញ្ហាសាក្សីនានា ដែលពុំមានឈ្មោះនៅក្នុងបញ្ជីបឋមរបស់ខ្លួន។ អង្គជំនុំជម្រះបានត្រឹមតែគូសបញ្ជាក់ថា ភាគីនៅតែមានលទ្ធភាពធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធទៅនឹងបុគ្គលដែលអាចធ្វើជាសាក្សីបន្ថែម និងបានធ្វើការកត់សម្គាល់ថាប្រសិនបើសវនាការ និងការលើកទឡ្ហីករណ៍ផ្ទាល់មាត់បន្ថែមមានភាពចាំបាច់ ខ្លួននឹងសម្រេចដូច្នេះក្នុងពេលវេលាមួយមិនជាក់លាក់[២៤]។ ភាសាដ៏សាមញ្ញងាយយល់នៃវិធាន ៨០*ស្ទួន* តម្រូវថា ការពិចារណាទៅលើបញ្ជីឈ្មោះសាក្សី គួរត្រូវបានធ្វើនៅឯ

[២៣] ឯកសារលេខ **E9/4/4.4** "ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ឧបសម្ព័ន្ធ ក៖ បញ្ជីឈ្មោះសាក្សីដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ (សម្រាប់អ្នកដែលមិនស្នើសុំនូវវិធានការការពារ) ក្រុមមេធាវីការពារក្ដី នួន ជា" ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១, លេខ ERN 00645893-00646073, ("បញ្ជីឈ្មោះសាក្សីរបស់លោក នួន ជា")។

[២៤] ឯកសារលេខ **E1/7.1,** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ", ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១, លេខ ERN 00713786, 00713816។

*សវនាការ* ដែលត្រូវតែបញ្ចូលនូវទទ្ធីករណ៍សំខាន់ៗអំពីសាក្សី ដែលភាគីបានស្នើសុំ[២៥]។ សវនាការនេះពុំទាន់បានប្រព្រឹត្តទៅនៅឡើយទេ ហើយអង្គជំនុំជម្រះសាលាដំបូងល្មើសនឹងកាតព្វកិច្ចរបស់ខ្លួនដោយអនុលោមតាមវិធាននេះ រហូតទាល់តែសវនាការនោះត្រូវបានធ្វើឡើង។ ភាគីយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវសម្រាប់ឲ្យមានសវនាការមួយ ដោយអនុលោមតាមវិធាន ៨០ *ស្ទួន* ដោយហេតុថាសំណើរបស់មេធាវីការពារក្ដីស្នើសុំឲ្យសវនាការបឋម ស្ដីពីបញ្ហាសាក្សីនានាដែលភាគីបានស្នើសុំបានទទួលការគាំទ្រពីសំណាក់ភាគីព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី[២៦]។

---

[២៥] ប្រយោគដំបូងនៃវិធាន៨០ *ស្ទួន* ចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវ 'ពិចារណា' អំពីបញ្ជីឈ្មោះសាក្សី ដែលដាក់ជូនដោយភាគីនៅសវនាការបឋម។ ប្រយោគទីពីរពិពណ៌នាអំពីកាលៈទេសៈ ដែលអង្គជំនុំជម្រះសាលាដំបូង អាច 'ពិចារណា'អំពីសាក្សីដែលនឹងមិនត្រូវកោះហៅ។ ការបកស្រាយវិធាន៨០ *ស្ទួន* គឺថា (i) ពាក្យ 'ពិចារណា' នៅក្នុងប្រយោគទាំងពីរមានអត្ថន័យដូចគ្នា (ពោលគឺ ពាក់ព័ន្ធនឹងការសម្រេចជាសារវន្តថាតើ ត្រូវកោះហៅសាក្សីជាក់លាក់ណាមួយ ឬមិនកោះហៅ និង (ii) ការសម្រេចនៅក្នុងប្រយោគទីពីរ គឺមានលក្ខណៈទូលំទូលាយជាង ដូចដែលមានពិពណ៌នានៅក្នុងវិធាន៨០ *ស្ទួន* (ពោលគឺសវនការបឋម)

[២៦] ឯកសារលេខ **E1/7.1,** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ", ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១, លេខ ERN 00713805, 00723806 ទំព័រ ៣៧-៣៨៖ ("លោក KOPPE: សូមអរគុណ លោកប្រធាន។ យើងខ្ញុំមានសំណើតែមួយគត់ស្នើសុំការបញ្ជាក់បំភ្លឺនិងវាជាអ្វីមួយដែលខ្ញុំយល់ថាគួរត្រូវបានពិភាក្សាជាសាធារណៈ ហើយយើងអាចធ្វើដូច្នោះក្រោយពេលសម្រាក។ ប៉ុន្តែ សំណើសុំការបញ្ជាក់បំភ្លឺគឺស្ដីអំពីវិធាន ៨០(ខ) ដែលជាវិធានស្ដីពីសវនាការបឋម។ យើងខ្ញុំយល់ថា បញ្ញត្តិដែលមានដូចខាងក្រោមនេះ ចែងថាអង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាអំពីបញ្ជីឈ្មោះមនុស្សដែលអាចធ្វើជាសាក្សីនៅឯសវនាការបឋម។ នាពេលបច្ចុប្បន្ននេះ យើងបានយល់ថាវិធាននេះបង្ហាញថា សវនាការបឋម គឺជាពេលវេលាពិភាក្សាជាសាធារណៈនូវសំណើសុំសាក្សីពីសំណាក់ភាគី ហើយ ភាគីព្រះរាជអាជ្ញាអាចជំទាស់ទៅនឹងសាក្សីនានា ដែលជនជាប់ចោទបានស្នើសុំ ហើយយើងអាចជំទាស់ទៅនឹងសាក្សីរបស់ភាគីព្រះរាជអាជ្ញា។ ហេតុដូច្នេះ ខ្ញុំចង់និយាយថាខ្ញុំកំពុងនិយាយអំពីសាក្សី ដែលពុំត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីបណ្ដោះអាសន្ន។ ហើយយើងខ្ញុំចង់ បានការណែនាំចំពោះពាក្យថា "ពិចារណា" ដូចដែលមាននៅក្នុងវិធាន ៨០(ខ)។ តើនឹងមានសវនាការបឋមមួយទៀត ដែលយើងអាចលើកអំណះអំណាងថាហេតុអ្វីសាក្សីរបស់យើងដែលពុំមានឈ្មោះនៅក្នុងបញ្ជីបណ្ដោះអាសន្ននេះ គួរមានឈ្មោះ នៅក្នុងបញ្ជីឈ្មោះសាក្សីស្ថាពរក្នុងដំណាក់កាលណាមួយ។ យើងខ្ញុំគ្រាន់តែចង់បានការបញ្ជាក់បំភ្លឺលើបញ្ហានោះប៉ុណ្ណោះ។ លោកប្រធាន៖ អញ្ជើញមេធាវីនាំមុខគឺលោកស្រី Fort។ លោកស្រី SIMONNEAU-FORT៖ លោកប្រធាន យើងក៏ជឿថាសវនាការបឋមមួយទៀតនឹងមានភាពចាំបាច់ ដើម្បីពិភាក្សាអំពីបញ្ជីទាំងនេះ ក្នុងចំណោមបញ្ហាផ្សេងៗ និងចំណុចច្បាប់នានា ហើយយើងចង់ទទួលបានការបញ្ជាក់បំភ្លឺបន្ថែម ពាក់ព័ន្ធនឹងសវនាការបឋមមួយទៀត ហើយយើងចង់ដឹងថាតើនៅពេលណាទើបសវនាការបឋមនេះអាចត្រូវបានកំណត់កាលបរិច្ឆេទ។ លោក SMITH៖ សូមអរគុណលោកប្រធាន។ ខ្ញុំប្រហែលជាលើកឡើងត្រួសៗប៉ុណ្ណោះ។ ភាគីព្រះរាជអាជ្ញាពិតជាគាំទ្រសវនាការសាធារណៈលើបញ្ហាទាំងនេះពេញទំហឹងតាមដែលអាចធ្វើទៅបាន ហើយយើងដឹងថា បញ្ហាមួយចំនួនពុំទាន់ត្រូវបានដោះស្រាយឡើយនៅថ្ងៃនេះ ហើយយើងដឹងអំពីដីការបស់លោកដែលបានគូសបញ្ជាក់ថាលោកនឹងជូនដំណឹងមកយើងក្នុងពេលឆាប់ៗ ពាក់ព័ន្ធនឹងវិធីដោះស្រាយបញ្ហា

**ខ. នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការដោយអនុលោមតាមវិធាន ៨០*ស្ទួន* សវនាការនេះត្រូវតែពាក់ព័ន្ធនឹងការលើកទឡ្ហីករណ៍ផ្ទាល់មាត់ជាសាធារណៈរបស់ភាគី នៅក្នុងសវនាការសាធារណៈ**

១៥. សវនាការតាមវិធាន ៨០ *ស្ទួន* គឺជាការចាំបាច់សម្រាប់ការលើកទឡ្ហីករណ៍ដោយផ្ទាល់មាត់។ ជាថ្មីម្តងទៀត ភាសាសាមញ្ញងាយយល់លាតត្រដាងថា៖ *សវនាការ* ជាចាំបាច់ត្រូវមានការធ្វើសន្និដ្ឋានដោយផ្ទាល់មាត់របស់ភាគីនៅតុលាការ[២៧]។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងការប្រជុំពិភាក្សាសម្រេចសម្ងាត់ ដោយពុំមានរយៈពេលកំណត់ច្បាស់លាស់ ពុំមែនជាសវនាការឡើយ។ ហេតុដូច្នេះ អនុលោមតាមវិធាននេះ អង្គជំនុំជម្រះសាលាដំបូងត្រូវស្នើសុំឱ្យភាគីលើកទឡ្ហីករណ៍ *ដោយផ្ទាល់មាត់* ដើម្បីគាំទ្រ ឬជំទាស់ទៅនឹងការកោះហៅសាក្សីនានាក្នុងអំឡុងសវនាការជាសាធារណៈ។

១៦. សិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈក៏គាំទ្រឱ្យមានសវនាការជាសាធារណៈ ដោយចំហដែរ។ ការជំនុំជម្រះក្តីលោក នួន ជា *ត្រូវតែ* ជាការជំនុំជម្រះជាសាធារណៈប្រសិនបើចង់បំពេញតម្រូវការសិទ្ធិមនុស្សជាមូលដ្ឋានរបស់គាត់ ដោយអនុលោមតាមកតិកាសញ្ញា ICCPR, សេចក្តីប្រកាស UDHR និងកិច្ចព្រមព្រៀងជាមួយនីតិវិធីរបស់ អ.វ.ត.ក រួមទាំងមាត្រា ៣៤ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧៩(៦)[២៨]។ សារៈសំខាន់នៃសវនាការសាធារណៈ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអាចត្រូវបានគូសបញ្ជាក់លើសពីនេះទៀត

---

ទាំងនោះ។ ប៉ុន្តែ យើងពិតជាចង់គាំទ្រមេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី ថាសវនាការនេះគួរធ្វើជាសាធារណៈឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ហើយជាការពិត ដោយសារទំហំនៃសវនាការនេះ ចំនួនជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ពិតជាមានបញ្ហាមួយចំនួនដែលត្រូវការដោះស្រាយមុនពេលការចាប់ផ្តើមនៃសំណុំរឿងនេះ។ ហើយដូច្នេះ យើងខ្ញុំគិតថា សវនាការបឋម កិច្ចប្រជុំរៀបចំសវនាការ និងកិច្ចប្រជុំប្រភេទនោះនៅក្នុងបន្ទប់សវនាការ ណាមួយបន្ថែមទៀត នឹងមានប្រយោជន៍ដើម្បីធានាបានថានៅពេលកិច្ចសវនាការចាប់ផ្តើម វានឹងប្រព្រឹត្តទៅដោយរលូន"។

[២៧] Bryan A. Garner ed., *Black's Law Dictionary*, ការកែសម្រួលលើកទី៩ (Thomson Reuters, ឆ្នាំ ២០០៩) ("សវនាការ ការជំនុំជម្រះ ដែលជាធម្មតាធ្វើឡើងជាចំហដល់សាធារណជន ដែលរៀបចំឡើងក្នុងគោលបំណងសម្រេចពីបញ្ហាអង្គហេតុ និងអង្គច្បាប់ ជួនកាលមានសាក្សីមកផ្តល់សក្ខីកម្មផងដែរ")។

[២៨] *សូមមើល ជើងទំព័រខាងលើ* III.B។

ឡើយ[២៩]។ ភាពជាសាធារណៈនៃកិច្ចដំណើរការនីតិវិធីគឺជាសិទ្ធិជាសារវ័ន្តមួយក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការពារប្រឆាំងនឹងការសម្រេចមិនត្រឹមត្រូវ និងពុំមានសំអាងហេតុត្រឹមត្រូវរបស់តុលាការ[៣០]។ ហេតុនេះ បញ្ហាគន្លឹះសំខាន់ៗទាំងអស់របស់ភាគី *ត្រូវតែ* ដោះស្រាយតាមរយៈកិច្ចដំណើរការនីតិវិធីជាសាធារណៈ។ ការស្ដាប់សក្ខីកម្មរបស់សាក្សីគឺជាបញ្ហាគន្លឹះដ៏សំខាន់មួយ។ ជាងនេះទៀត ដើម្បីអនុញ្ញាតឲ្យប្រជាជនកម្ពុជាទទួលស្គាល់កិច្ចការរដ្ឋបាលរបស់តុលាការ[៣១] និងដើម្បីឲ្យសារព័ត៌មានរាយការណ៍ និងដើរតួនាទីជាអ្នកឃ្លាំមើលកិច្ចដំណើរការនីតិវិធី តុលាការមានកាតព្វកិច្ចធ្វើឲ្យសវនាការទាំងមូលរបស់លោក នួន ជា ជាសាធារណៈឲ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន។

១៧. ទីបញ្ចប់ ទទ្ធីករណ៍ផ្ទាល់មាត់គឺជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការកំណត់អត្តសញ្ញាណសាក្សីសម្រាប់សវនាការ ជាដំណើរការដ៏វែងនៃការរៀបចំសេចក្ដីព្រាង និងការផ្លាស់ប្ដូរសារណាជាលាយលក្ខណ៍អក្សរផ្លូវការ។ ភាពពាក់ព័ន្ធនៃសាក្សីជាក់លាក់អាស្រ័យមួយផ្នែក ទៅលើភាព

---

[២៩] *ជើងទំព័រខាងលើ* III.B។ *សូមមើលផងដែរ រឿងក្ដី* Werner ទល់នឹង *ប្រទេសអូទ្រីស*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, "សាលក្រម", ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧, កថាខណ្ឌ ៤៥ (លក្ខណៈសាធារណៈនៃកិច្ចដំណើរការនីតិវិធី "ការពារគូភាគីពីកិច្ចការរដ្ឋបាលរបស់តុលាការដោយសម្ងាត់ ដោយពុំមានការត្រួតពិនិត្យជាសាធារណៈ។ វាក៏ជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានាដែលទំនុកចិត្តលើតុលាការ ថ្នាក់លើ និងថ្នាក់ក្រោម អាចត្រូវបានរក្សា។ តាមរយៈការធ្វើឲ្យកិច្ចការរដ្ឋបាលរបស់តុលាការមានតម្លាភាព ការផ្សាយជាសាធារណៈរួមចំណែកដល់ការសម្រេចបាននូវគោលបំណងនៃមាត្រា៦(១) ពិសេស គឺការជំនុំជម្រះដោយយុត្តិធម៌ ដែលការធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌ គឺជាគោលការណ៍ជាមូលដ្ឋានមួយក្នុងចំណោម គោលការណ៍ទាំងឡាយនៃសង្គមប្រជាធិបតេយ្យទាំងឡាយ នៅក្នុងអត្ថន័យនៃអនុសញ្ញា")។

[៣០] *សូមមើល ជើងទំព័រខាងលើ,* កថាខណ្ឌ ៧-៨។

[៣១] ដោយសារតែ ១,៣ នាក់ប៉ុណ្ណោះក្នុងចំណោមប្រជាជនកម្ពុជា ១០០ នាក់បានប្រើប្រាស់អ៊ីនធឺណែត ទើបសារណាជាលាយលក្ខណ៍អក្សរគឺជាសារណាមិនសាធារណៈ ដោយសារគេអាចមើលសារណាទាំងនោះបានតែតាមរយៈគេហទំព័ររបស់តុលាការតែប៉ុណ្ណោះ។ សារណាផ្ទាល់មាត់ អាចត្រូវបានផ្សព្វផ្សាយតាមវិទ្យុ តាមបណ្ដាញសារព័ត៌មាន និងតាមការពិភាក្សាជាសាធារណៈ។ *សូមមើល* "កម្ពុជា" *ទិន្នន័យ* ធនាគារពិភពលោក (ចូលមើលចុងក្រោយថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២) អាចរកបាននៅលើគេហទំព័រ៖ http://data.worldbank.org/country/cambodia។ នៅកម្ពុជា សារណាជាលាយលក្ខណ៍អក្សរ ជាពិសេសទៅលើបញ្ហាសំខាន់ៗស្មុគស្មាញ និងវែងអន្លាយ មិនអាចឲ្យសាធារណជនអាចពិនិត្យពិច័យបានទេ។ អង្គជំនុំជម្រះតុលាការកំពូលបានអះអាងសាជាថ្មីពីសារៈសំខាន់នៃការយល់ដឹងរបស់សាធារណជន និងការពិភាក្សាដេញដោលយោបល់ទៅលើសេចក្ដីសន្និដ្ឋានរបស់ អ.វ.ត.ក។ *សូមមើល* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជតក, ឯកសារលេខ F-28, "សាលដីកាលើបណ្ដឹងសាទុក្ខ" ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២, 00797698-00798047, កថាខណ្ឌ ៧០៨។

ពេញលេញនៃភស្តុតាងដទៃទៀតដែលត្រូវបង្ហាញ និងមិនអាចត្រូវបានវាយតម្លៃឲ្យបានពេញលេញ ដោយផ្អែកលើភស្តុតាងនីមួយៗ ដោយមិនបានដឹងពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះចំពោះសាក្សីដទៃទៀតតែមានករណីស្រដៀងគ្នានោះទេ។ ធនធានរបស់ភាគី អង្គជំនុំជម្រះ និងសេវាបកប្រែឯកសារដែលឧបត្ថម្ភដោយតុលាការ មានភាពប្រសើរសម្រាប់នីតិវិធីឆ្លើយឆ្លងគ្នាដោយផ្ទាល់មាត់ជាងការផ្ញើសារណាមួយម្តងៗចុះឡើងៗដែលមានភាពស្មុគស្មាញ។

**គ. អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើសវនាការ ដោយអនុលោមតាមវិធាន ៨០ *ស្ទួន* ឆាប់ៗតាមដែលអាចធ្វើទៅបាន ដើម្បីបញ្ចៀសការរំលោភណាមួយបន្ថែមទៀតទៅលើសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌**

១៨. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថានៅពេលណាមួយ ខ្លួននឹងសម្រេចថាតើត្រូវកោះហៅសាក្សីដែលលោក នួន ជា បានស្នើសុំដែរ ឬយ៉ាងណា។ ទោះជាបែបនេះក្តី ការអូសបន្លាយពេលរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការធ្វើសវនាការ ដោយអនុលោមតាមវិធាន ៨០*ស្ទួន* រំលោភលើសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី និងការការពារខ្លួន។

១៩. ទោះបីសំណើរបស់មេធាវីការពារក្តីសុំឲ្យសាក្សីចំនួន ៥២៧នាក់ មកផ្តល់សក្ខីកម្មដើម្បីគាំទ្រលោក នួន ជា ក៏ដោយ ក៏បញ្ជីបឋមរបស់អង្គជំនុំជម្រះសាលាដំបូងជ្រើសរើសយកតែសាក្សី *ពីរនាក់* ដើម្បីផ្តល់សក្ខីកម្មដោះបន្ទុកទាំងស្រុង[៣២]។ សិទ្ធិរបស់លោក នួន ជា ក្នុងការការពារខ្លួន[៣៣] ទាមទារ

[៣២] ទោះបីសាក្សីជាក់លាក់មួយចំនួននៅក្នុងបញ្ជីឈ្មោះសាក្សីរបស់អង្គជំនុំជម្រះសាលាដំបូងមាននៅក្នុងបញ្ជីឈ្មោះសាក្សីដែលបានស្នើសុំដោយលោក នួន ជា លើកលែង TCW-425 និង TCW-482 ក៏ដោយ ក៏ឈ្មោះសាក្សីទាំងនេះក៏ត្រូវបានស្នើសុំដោយព្រះរាជអាជ្ញា ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ។ មានតែ TCW-425 និង TCW-482 ទេដែលត្រូវបានជ្រើសរើសដើម្បីបង្ហាញពីភាពវិជ្ជមានរបស់មេធាវីការពារក្តី។ (ឯកសារលេខ **E131/1.1**, "ឧបសម្ព័ន្ធសម្ងាត់ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២" ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ លេខ ERN 00747687-00747694)។ លោក នួន ជា បានស្នើសុំឈ្មោះសាក្សីចំនួនរាប់រយដែលមិនមាននៅក្នុងបញ្ជីរបស់ ក.ស.ព។ (ប្រៀបធៀបឯកសារលេខ **E9/4.1**, "ឧបសម្ព័ន្ធ ១៖ សំណើបង្គាប់ឲ្យសាក្សីចូលបង្ហាញខ្លួនក្នុងសវនាការ" ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១, លេខ ERN 00640745-00640778 (ដែលបានស្នើសុំឈ្មោះសាក្សីសរុបចំនួន ២៧៩ រួមទាំងសាក្សីបញ្ជាក់អត្តហេតុចំនួន ២៧៩) ជាមួយបញ្ជីឈ្មោះសាក្សីរបស់លោក នួន ជា (ដែលបានស្នើសុំឈ្មោះសាក្សីបញ្ជាក់អត្តហេតុចំនួន ៥២៧))។

ឱ្យគាត់អាចមានលទ្ធភាពបង្ហាញទស្សនៈផ្ទាល់របស់គាត់ចំពោះសំណុំរឿង រួមមានការប្រើប្រាស់សក្ខីកម្ម និងភស្តុតាងផ្សេងៗ។ បញ្ជីឈ្មោះសាក្សីនាពេលបច្ចុប្បន្ន រំលោភសិទ្ធិនោះ ដោយសារបញ្ជីនោះនឹងមិនផ្តល់ឱកាសឱ្យមេធាវីការពារក្តីបញ្ជាក់អះអាងលើទ្រឹស្តីរបស់ខ្លួន ចំពោះសំណុំរឿងនេះដោយភាពសុទិដ្ឋិនិយមឡើយ។ ការសួរដេញដោលរបៀបការពារខ្លួននេះពុំអនុញ្ញាត ឱ្យមេធាវីការពារក្តីបំផុសផ្នែកនៃរឿងរ៉ាវរបស់លោក នួន ជា ឬស្វែងយល់អំពីការបកស្រាយហេតុការណ៍ទាំងឡាយ ខាងក្រៅក្របខ័ណ្ឌនៃរបាយការណ៍របស់ភាគីព្រះរាជអាជ្ញាទេ។

២០. ការខកខានមិនធ្វើឱ្យសិទ្ធិរបស់លោក នួន ជា ក្នុងការការពារខ្លួនមានប្រសិទ្ធភាពតាមរយៈសាក្សីដោះបន្ទុកនោះ ត្រូវបានបង្កើតឡើងនៅក្នុងដំណើរការរៀបចំសវនាការតាំងពីពេលចាប់ផ្តើមដំបូងមកម្ល៉េះ។ ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ដែលចេញដោយអង្គជំនុំជម្រះមុនកិច្ចប្រជុំរៀបចំសវនាការបានណែនាំឱ្យភាគី ក្នុងការបង្ហាញពីកថាខណ្ឌនានាក្នុងដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីម្នាក់ៗរបស់ខ្លួន[៣៤]។ ហេតុនេះ រាល់សក្ខីកម្មទាំងអស់ត្រូវបានសន្មតថា បានបង្ហាញ ឬមិនបានបង្ហាញពីអង្គហេតុតាមលំដាប់លំដោយដែលត្រូវបានបង្កើតឡើងដោយចៅក្រមស៊ើបអង្កេត និងបានចែកជូនភាគីជាឯកសារក្រដាសនៃដីកាដំណោះស្រាយ។ តែភស្តុតាងនៃសំណុំរឿងដោះបន្ទុករបស់លោក នួន ជា មិនស្របទៅនឹងការលើកឡើងទាំងមូលដែលបង្ហាញដោយចៅក្រមស៊ើបអង្កេតទេ។

២១. ការដែលមេធាវីការពារក្តីពុំអាចការពារសំណុំរឿងរបស់ខ្លួនដោយសុទិដ្ឋិនិយមបានឡើយ គឺជាការរំលោភលើសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី។ បញ្ជីឈ្មោះសាក្សីបឋម ដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ប្រយោជន៍ដល់ភស្តុតាងដាក់បន្ទុកយ៉ាងលើសលប់[៣៥]។ បញ្ជីនេះខកខានមិនបាន "ធានាថា [ត្រូវមាន] សមាមាត្រ

---

[៣៣] *សូមមើលជើងទំព័រខាងលើ* III.D។

[៣៤] ឯកសារលេខ **E9**, "ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ" ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, លេខ ERN 00635754-00635759, កថាខណ្ឌ 6(iii)។

[៣៥] ក្នុងចំណោមឈ្មោះសាក្សីចំនួន ៦៥ នៅក្នុងបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង សាក្សីចំនួន ២៨ ត្រូវបានស្នើសុំដោយព្រះរាជអាជ្ញា ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែឯង។ ផ្ទុយទៅវិញ មានឈ្មោះសាក្សីសរុបចំនួន ៦ ពីមេធាវីការពារក្តីទាំង ៤ ក្រុមរួមគ្នាត្រូវបានជ្រើសរើស ដោយពុំស្មើនឹងចំនួនដែលបានទទួលយកដោយព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ *សូមមើល* ឯកសារលេខ **E131/1.1**, "ឧបសម្ព័ន្ធសម្ងាត់ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹង

ជាមូលដ្ឋាន រវាងពេលវេលា និងចំនួនសាក្សី ដែលត្រូវផ្តល់ឲ្យទៅភាគីទាំងអស់"[៣៦] និងធ្វើឲ្យលោក នួន ជា បាត់បង់ផលប្រយោជន៍ទៅខាងភាគី [ព្រះរាជអាជ្ញា]"[៣៧]។

២២. ដោយសារសវនាការកំពុងដំណើរការទៅមុខនោះ ស្ថានភាពនេះកំពុង និងបន្តរំលោភដល់សិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានសវនាការដោយយុត្តិធម៌។ ទោះបីនៅទីបំផុត សាក្សីខ្លះក្នុងចំណោមសាក្សីទាំងនេះត្រូវបានអង្គជំនុំជម្រះកោះហៅក៏ដោយ តែការពុំបានដឹងជាមុនពីសេចក្តីសម្រេចទាំងនេះនោះ មេធាវីការពារក្តីបានត្រឹមតែអាចធ្វើការប៉ាន់ស្មាន និងអនុវត្តវិធីសាស្ត្រ ដើរមួយជំហានគិតមួយជំហានទៅលើយុទ្ធសាស្ត្រនៃការជំនុំជម្រះរបស់ខ្លួនតែប៉ុណ្ណោះ។ មេធាវីការពារក្តីត្រូវបានបង្ខំឲ្យរៀបចំព័ត៌មានសម្រាប់សវនាការពុំបានស៊ីជម្រៅ ដូចភាគីព្រះរាជអាជ្ញាទេ។ ប្រការនេះធ្វើឲ្យមេធាវីការពារក្តីមិនអាចការពារក្តីរបស់ខ្លួន និងធ្វើឲ្យខ្លួនបាត់បង់អត្ថប្រយោជន៍ទល់នឹងគូបដិបក្ខរបស់ខ្លួន។ ទាំងសិទ្ធិក្នុងការការពារក្តី និងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយក្នុងកាលតទល់ក្តីត្រូវបានរំលោភ។

២៣. លើសពីនេះទៀត មេធាវីការពារក្តីពុំអាចលើកឡើងនូវឈ្មោះរបស់សាក្សីទាំងឡាយដែលភាគីស្នើសុំ ឬពិភាក្សាអំពីព័ត៌មានពាក់ព័ន្ធអត្តសញ្ញាណរបស់សាក្សីនៅតុលាការបានឡើយ មុនពេលសវនាការតាមវិធាន ៨០*ស្ទួន*[៣៨]។ លោក នួន ជា ពុំអាចការពារខ្លួនបានត្រឹមត្រូវឡើយ ប្រសិនបើមេធាវីរបស់គាត់ត្រូវបានហាមឃាត់មិនឲ្យពិភាក្សាជាមួយមនុស្សសំខាន់ៗ ដែលមានឥទ្ធិពលទៅលើហេតុការណ៍នានានៅកម្ពុជាក្នុងអំឡុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការអូស

---

រដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២" ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ លេខ ERN 00747687-00747694។

[៣៦] សំណុំរឿងលេខ IT-04-74-AR73.4, *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić,* 'សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាបន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើការបញ្ជូនត្រឡប់វិញ និងការបញ្ជាក់បន្ថែម' ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០០ កថាខណ្ឌ ៣៨។

[៣៧] សំណុំរឿងលេខ IT-94-1-A, *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić,* "សាលក្រម" ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៤៨, ដោយដកស្រង់ចេញពី *រឿងក្តី Dombo Beheer B.V. តទល់នឹង ប្រទេសហូឡង់,* ECtHR (14448/88), "សាលក្រម" ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៤០។

[៣៨] ឯកសារលេខ **E1/4.1**, "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ", ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១, លេខ ERN ERN 00712135-00712252 ទំព័រ ៤០-៤១។ *សូមមើលផងដែរ* ឯកសារលេខ **E1/7.1**, "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ", ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១, ERN 00713767-00713819 ទំព័រ ១៣-១៧។

បន្ទាយពេលរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការធ្វើសវនាការ ដោយអនុលោមតាមវិធាន ៨០ *ស្ទួន* ដើរតួនាទីជាដីកាហាមឃាត់ការពិភាក្សារបស់មេធាវីការពារក្តីអំពីឈ្មោះសំខាន់ៗ និងប្រធានបទក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន។ ជាថ្មីម្តងទៀត មេធាវីការពារក្តីមិនអាចការពារក្តីរបស់ខ្លួនបានពេញលេញទេ។

២៤. ដើម្បីកាត់បន្ថយព្យសនកម្មបន្ថែមណាមួយដែលមានចំពោះសិទ្ធិរបស់លោក នួន ជា ក្នុងការការពារខ្លួន និងសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី អង្គជំនុំជម្រះសាលាដំបូងមិនត្រូវអូសបន្លាយពេលតទៅទៀតឡើយ ក្នុងការធ្វើសវនាការដោយអនុលោមតាមវិធាន ៨០*ស្ទួន* ដើម្បីសម្រេចថាតើសាក្សីណាខ្លះរបស់មេធាវីការពារក្តីនឹងត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម។

### ឃ. អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចអនុញ្ញាតឱ្យមេធាវីការពារក្តី លើកបញ្ហាទាំងនេះដោយយោងទៅលើសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌

២៥. ជាចុងក្រោយ វិធានខាងលើបង្គាប់ឱ្យប្រធានអង្គជំនុំជម្រះសាលាដំបូង[៣៩] អនុញ្ញាតឱ្យមានការអនុវត្តដោយសេរីនូវសិទ្ធិរបស់មេធាវីការពារក្តី។ អាស្រ័យហេតុនេះ គាត់មានកាតព្វកិច្ចយល់ថាមេធាវីការពារក្តីអាចអនុវត្តសិទ្ធិទាំងអស់របស់ខ្លួននៅក្នុងសំណុំរឿងនេះ រួមទាំងសិទ្ធិការពារខ្លួនសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី និងសិទ្ធិទទួលបានសវនាការជាសាធារណៈ។ ហេតុនេះក្រោមការណែនាំរបស់ប្រធានអង្គជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែគោរពសិទ្ធិរបស់លោក នួន ជា និងដោះស្រាយបញ្ហាដែលអនុញ្ញាតឱ្យសាក្សីដែលនិយាយជំនួសមុខឱ្យលោក នួន ជា ផ្តល់សក្ខីកម្មតាមរយៈការស្តាប់សក្ខីកម្មសាក្សីដោយអនុលោមតាមវិធាន ៨០*ស្ទួន* ។

### ង. សំណើរបស់មេធាវីការពារក្តីស្នើសុំឱ្យមានសវនាការតាមវិធាន ៨០*ស្ទួន* គឺជាសំណើទាន់ពេលវេលា

២៦. នៅឯសវនាការជាសាធារណៈជាលើកដំបូងកាលពីខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធពុំស្នើសុំឱ្យមានទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធនឹងសាក្សី ដែលពុំមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីបឋមរបស់ខ្លួន។ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថាប្រសិនបើសវនាការ និង

[៣៩] វិធាន ៨៥(១)។

ទទ្បីករណ៍ផ្ទាល់មាត់បន្ថែមបង្ហាញពីភាពចាំបាច់ ខ្លួននឹងសម្រេចដូច្នេះនៅក្នុងពេលសមស្រប[៤០]។ នៅទីបំផុត អង្គជំនុំជម្រះសាលាដំបូងពុំទាន់បានធ្វើសវនាការ ឬពុំបានស្នើសុំឲ្យមានការលើកទទ្បីករណ៍លើប្រធានបទនេះនៅឡើយទេ។ កាលពីខែ កុម្ភៈ ឆ្នាំ ២០១២ កន្លងទៅ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នៅក្នុងអនុស្សរណៈមួយថា ខ្លួននឹងចេញបញ្ជីបឋមនៃឈ្មោះសាក្សី អ្នកជំនាញ និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណីដែលខ្លួនបានបដិសេធ នាពេលឆាប់ៗ[៤១]។ ជាង ៤ ខែក្រោយមកទៀត អង្គជំនុំជម្រះពុំទាន់បានចេញបញ្ជីនេះនៅឡើយទេ។ មកទល់នឹងពេលបច្ចុប្បន្ន មេធាវីការពារក្តីពុំបានដឹងថាតើសាក្សីដែលខ្លួនបានស្នើសុំ នឹងត្រូវបានស្តាប់សក្ខីកម្ម ឬយ៉ាងណាឡើយ។ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងមានពេលវេលាច្រើនក្នុងការចេញបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណីដែលខ្លួនបដិសេធ "នាពេលឆាប់ៗខាងមុខ" និងដោយសារកង្វះចំណាត់ការច្បាស់លាស់របស់អង្គជំនុំជម្រះក្នុងការសម្រេចលើបញ្ជីឈ្មោះសាក្សីស្ពាពរ ទើបសំណើនេះជាសំណើមួយដែលទាន់ពេលវេលា។

## ច. សេចក្តីសន្និដ្ឋាន និងសំណូមពរ

២៧. តាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះសាលាដំបូងគួរគប្បីរៀបចំសវនាការ ដោយអនុលោមតាមវិធាន៨០*ស្ទួន* និងស្នើសុំឲ្យភាគីធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ដើម្បីសម្រេចថាតើសាក្សី និងអ្នកជំនាញណាខ្លះ នៅក្នុងបញ្ជីឈ្មោះសាក្សីដែលបានស្នើសុំដោយលោក នួន ជា នឹងត្រូវកោះហៅឲ្យចូលខ្លួនមកផ្តល់សក្ខីកម្មនៅសវនាការ។

សហមេធាវីរបស់លោក នួន ជា

**សុន អរុណ** Michiel PESTMAN & Victor KOPPE

[៤០] ឯកសារលេខ **E1/7.1**, "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១, ERN 00713767-00713819 ទំព័រ ១៨។

[៤១] ឯកសារលេខ **E172**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ៤។